# យួនជាន់ខ្មែរព្រោះសីហនុ

Dear All,  I hope you are all Cambodian young generation would not build hatred and retaliation towards past Khmer leaders such as Somdech Norodom Sihanouk or Pot Pol until they call "Khmers bite Khmers but benefits foreigner such Vietnam".

គប្បីយើងកុំប្រឡំរវាង សម្អប់សងសឹក និង ការទទួលខុសត្រូវ ។ មនុស្សដូចជា នរោត្តម សីហនុ គឺជាជនមានតួនាទីដឹកនាំ ហើយតួនាទីនេះមានទាំងកាតព្វកិច្ច និងភារកិច្ច និងការទទួលខុសត្រូវ ។ ចូរយើងក្រឡេកមើលប្រវត្តិសាស្រ្ត ថាតើអ្វីដែល សីហនុ បានធ្វើកន្លងមកជាទំរើប្រែកបដោយធនធ្ងុះជាតិ ឬក៏ជាទំរើអត្តនោម័តដើម្បីបំពេញចិត្តខ្លួន?

យើងក៏ឃើញថា សីហនុ បានធ្វើប្រយោជន៍ជាតិជាច្រើន ។ ទន្ទឹមគ្នានេះ យើងក៏បានឃើញថាគាត់ធ្វើតាមទំនើងចិត្តច្រើនណាស់ដែរ ។  អំពើតាមទំនើងចិត្តនេះ ជាភារកិច្ចទទួលខុសត្រូវរបស់គាត់ចំពោះប្រជាជាតិ ដែលទំរើតាមទំនើងចិត្តនោះ បានបំផ្លិចបំផ្លាញ ឲ្យវិនាសអន្តរាយ អស់ទ្រព្យសម្បត្តិ និងអាយុជីវិតមនុស្សជាច្រើនលាននាក់ ។

រាល់សមិទ្ធិផលកសាងដោយនយោយ សីហនុ ពីឆ្នាំ១៩៤១ ដល់ឆ្នាំ១៩៧០ បានត្រូវ សីហនុ ខ្លួនឯងបំផ្លាញចោលសឹងទាំងអស់ ។ យើងអាចរាប់ចាប់ពីឯករាជ្យភាពកម្ពុជា អព្យាក្រឹត្យភាព សាម-គ្គីភាពជាតិ សេដ្ឋកិច្ចជាតិ និងបូរណៈភាពដែនដីកម្ពុជា សុទ្ធតែបានត្រូវ សីហនុ បំផ្លាញចោលអស់គ្មានសល់ឡើយ ។

ក្នុងខ្សែភាពយន្តឯកសារមួយចំណងជើងថា <<ព្រះអង្គម្ចាស់ និងព្យាករណ៍>> ដែលគេបានធ្វើសម្ភាសន៍ជាមួយ សីហនុ, គាត់បាននិយាយអះអាងថា ប្រសិនបើគាត់មិនបានត្រូវគេរំលំទេនោះ គាត់ច្បាស់ជាអាចថែរក្សាឯករាជ្យ និងបូរណៈភាពទឹកដីកម្ពុជាបានជាមិនខាន ហើយបញ្ហាយួនកុម្មុយ-នីស្ត យៀកកុង ដែលតាំងមូលដ្ឋានលើទឹកដីខ្មែរ ក៏គាត់អាចដោះស្រាយបានដែរ ។ ត្រង់នេះគឺជាសំដីកូតកុហករបស់ សីហនុ សុទ្ធសាត ។

ព្រឹត្តិការណ៍ក្នុងអំឡុងឆ្នាំ១៩៦០ និងឆ្នាំ១៩៧០ បានបង្ហាញឲ្យដឹងថា សីហនុ ផុងខ្លួនយ៉ាងជ្រៅក្នុងនយោបាយលំអៀងចូលកុម្មុយនីស្ត និងចូលយួន រហូតដល់គាត់ដោះស្រាយមិនរួច ។ ដោយសារតែបញ្ហានេះ គាត់ក៏ចាកចេញពីប្រទេសកម្ពុជានៅខែមករាឆ្នាំ១៩៧០ ។ កិរិយារត់ចោលបញ្ហាទៅជ្រកនៅឯបរទេសរបស់គាត់ បានត្រូវគេដឹងសឹងគ្រប់ពេល ព្រោះវាជាទំរើញឹកញាប់ណាស់របស់គាត់ ។

នៅដើមឆ្នាំ១៩៧០នោះ សីហនុ បានរត់គេចទៅបរទេសដោយសារតែបញ្ហាជិតក្បែយធនថៃ សេដ្ឋកិច្ចជាតិ និងបញ្ហាយួនកុម្មុយនីស្តកាន់កាប់ទឹកដីខ្មែរ មិនព្រមដកថយសោះ ។ គាត់ក៏បានលើកសំពាយបញ្ហានោះដាក់ទៅឲ្យលោក លន់ នល់ និងទ្រង់ ស៊ីសុវត្ថិ សិរិមៈតៈ ដោះស្រាយ ។ គាត់បានអនុញ្ញាតឲ្យរដ្ឋាភិបាលចុងក្រោយរបស់លោក លន់ នល់ ផ្លាស់ប្តូរ និងកែប្រែនយោបាយជាតិដើម្បីដោះស្រាយបញ្ហាធំៗដែល សីហនុ និងអាម៉ីអាថោងគាត់បានបង្កើតឡើង ។

ក្នុងអំឡុងពេលដែលរដ្ឋាភិបាលលោក លន់ នល់ កំពុងខិតខំកែប្រែដោះស្រាយបញ្ហាប្រទេស សីហនុ ស្រាប់តែប្រែចិត្តលែងគាំទ្រទំរើរបស់រដ្ឋាភិបាល ដែលកាលពីខែកញ្ញាឆ្នាំ១៩៦៩ រូបគាត់បានអនុញ្ញាតឲ្យធ្វើការកែប្រែនយោបាយ និងឲ្យសិទ្ធិអំណាចពេញលេញ ដើម្បីដោះស្រាយបញ្ហាធំៗរបស់

ជាតិ ។ កិរិយាផ្លាស់ប្តូរចិត្តរបស់ សីហនុ ធ្វើឡើងដូចកូនក្មេងបៀមដៃ ។ គាត់ធ្វើស្រេចនឹងចិត្តគាត់ ដែលមិនមាននរណាអាចប្រព្រឹត្តតាមគាត់ទាន់ ។ គាត់ឲ្យរដ្ឋាភិបាលដោះស្រាយបញ្ហាយួនកុម្មុយនីស្ត ស្រាប់តែគាត់បដិសេធនឹងលែងទទួលដឹង រួចហើយបែជាថ្កោលទោសរដ្ឋាភិបាលថាបានបង្កលក្ខណៈឲ្យមានវិប័តជាមួយយួនកុម្មុយនីស្តទៅវិញ ។

ភាពក្រឡិចក្រឡុចនេះ បានឈានដល់អំពើក្បត់ជាតិឯង នៅពេលដែល សីហនុ បានទទួលឲ្យយួនកុម្មុយនីស្ត យៀកកុង លើកទ័ពវាយប្រហារកាប់សម្លាប់ខ្មែរ ក្នុងនាមគាត់សុទ្ធសាត ។ សង្គ្រាមឈ្លានពានមកលើកម្ពុជាត្រូវបាន សីហនុ ជួយបឺតបាំង ។ គាត់បានក្លាយជាមេក្លោងបំផ្លាញប្រទេសជាតិឯង ដែលជាទំរើគាត់បន្តប្រព្រឹត្តរហូតដល់សព្វថ្ងៃនេះ ។

សេចក្តីរៀបរាប់ខាងលើនេះ គឺជាសាច់រឿងសង្ខេបអំពីសកម្មភាពនយោបាយផ្ទុយពីប្រយោជន៍ជាតិធ្វើឡើងដោយ សីហនុ ហើយជាអំពើគាត់ត្រូវទទួលខុសត្រូវចំពោះមុខប្រជាជាតិខ្មែរ ។ វាមិនមែនជាសម្អប់សងសឹកឡើយ ។

សាធារណៈជនខ្មែរមានសិទ្ធិគ្រប់គ្រាន់ នឹងប្រកាសថ្កោលទោស សីហនុ ។ ទោះបីជាគាត់ខិតខំចូលដៃកុម្មុយនីស្ត រៀបចំការពារខ្លួនគាត់យ៉ាងណាក៏ដោយ ក៏គាត់មិនអាចគេចរួចពីការប្រកាសថ្កោលទោសនេះដែរ ។ បើគេមិនអាចកាត់ទោសគាត់បានតាមផ្លូវច្បាប់ ក៏គេអាចកាត់ទោសគាត់តាមផ្លូវប្រវត្តិសាស្ត្របានដែរ ។ នេះជាភាវៈដែលកើតឡើងមិនអាចគេចរួចឡើយ ។

As I have balance my very limited ability, I can see that human beings are not perfect, they have both sides of good and bad; and we should not extremely accuse or reteliate them in evil side only.

គប្បីយល់ឲ្យច្បាស់ថាមនុស្សមិនមែនធ្វើត្រូវទាំងអស់នោះទេ តែកុំប្រឡំថាទោសកំហុសធ្ងន់ធ្ងរអាចកើតឡើងដោយទំរើមនុស្សរាល់រូបឡើយ ។ សីហនុ បានធ្វើកំហុសធ្ងន់ធ្ងរចំពោះប្រជាជាតិខ្មែរ ដែលទោសកំហុសនេះ មិនមែនស្រាលអាចបំភ្លេចចោលនោះឡើយ ព្រោះវាជាអំពើបណ្តាលឲ្យប្រទេសទាំងមូលទទួលខូចខាតធ្ងន់ធ្ងរណាស់ ។ ជីវិតមនុស្សរាល់លាននាក់បានត្រូវស្លាប់ដោយសារតែនយោបាយឆ្គួតលីលារបស់គាត់ ។

Khmer people have to unite together to find out who is Khmer's real enemy?

សត្រូវអាចជ្រៀតចូលមករំលោភលើខ្មែរបាន ដោយសារមានមនុស្សក្បត់ជាតិឯងដូចតួយ៉ាង សីហនុ នេះ ។ នៅខែមិនាឆ្នាំ១៩៧០ ប្រសិនបើ សីហនុ មិនចូលដៃយួនកុម្មុយនីស្ត ឲ្យវាមកសម្លាប់ខ្មែររួមជាតិនឹងគាត់ នោះក៏ប្រជាជាតិខ្មែរមិនបែកបាក់សាមគ្គីជាតិដែរ ។ ប្រសិនបើគាត់មិនចូលនឹងយួនកុម្មុយនីស្ត ក៏ពួកខ្មែរក្រហមមិនចូលនឹងគាត់ រួចរីកចំរើនរហូតដល់ក្លាយជាអង្គការដ៏ចង្រៃសាហាវព្រៃផ្សៃបំផុតនោះឡើយ ។

ប្រសិនបើ សីហនុ មិនក្រឡាស់កែប្រែគំនិត នោះគាត់ក៏មិនត្រូវគេផ្តួលរំលំចោលដែរ ។ រដ្ឋសភាមិនចង់ដកសេចក្តីទុកចិត្តពីគាត់ឡើយ ព្រោះពួកគេគោរពគាត់ខ្លាំងណាស់ ។ រាស្ត្រខ្មែរភាគច្រើន

ស្រឡាញ់គាត់ ។ គឺរូបគាត់ទេតើដែលបង្កភាពចលាចល រហូតដល់មានការរំលំគាត់ចេញពីតំណែង នៅថ្ងៃទី ១៨ មិនា ១៩៧០ ។

ដូច្នេះសូមជ្រាបថាបើគ្មានខ្មោចចង្រៃដូច សីហនុ ឲ្យដៃយួន ក៏វាមិនអាចបំពានលើខ្មែរបានដូចសព្វថ្ងៃនេះដែរ ។ សព្វថ្ងៃនេះទៀតសោត សីហនុ និងគ្រួសារនៅតែចូលដៃនឹងពួកកុម្មុយនីស្ត ។ ឧទា-ហរណ៍ជាក់ស្តែងគឺរឿងព្រំដែន ។ សីហមុនី បន្តរាជ្យពី សីហនុ ក៏បានធ្វើដូចជាឪពុកខ្លួន ដោយទទួលស្គាល់ទំរើខុសច្បាប់របស់យួន និងអាយ៉ង ។

Or Khmers should use controversial opinions and activities as the driving force to develop and promote Khmer country, not use it like cats and dogs until cannot see who is real enemy...
Ignorance leads to suffering and disappearing of Khmer land!
Cambodian View

វាជាការយល់ច្រឡំធ្ងន់ធ្ងរណាស់ ដែលយើងត្រូវប្រមាទខ្លួនយើងថាជាសត្វឆ្កែ ព្រោះតែយើងលើករឿងថ្កោលទោសចំពោះ សីហនុ ។ យើងក៏យល់ខុសដែរ ដែលគិតថាថ្កោលទោស សីហនុ នឹងធ្វើឲ្យយើងរលំរលាយវិនាសបាត់អស់ទឹកដីនោះ ។ ផ្ទុយទៅវិញភាពល្ងង់ខ្លៅរបស់យើងទេតើដែលឲ្យ សីហនុ រួចខ្លួន ហើយបណ្តាលឲ្យគាត់ និងគ្រួសារសេពគបជាមួយកុម្មុយនីស្ត រហូតដល់យើងវិនាសអន្តរាយដូចសព្វថ្ងៃនេះ ។

ដូច្នេះ ចូរយើងភ្ញាក់ឡើង ក្រឡេកមើលប្រវត្តិសាស្ត្រឲ្យច្បាស់ បែងចែកឲ្យបានល្អ ថាតើយើងកំពុងតែរងទុក្ខសព្វថ្ងៃនេះ ដោយសារតែយួន ឬក៏ដោយសារតែ សីហនុ គ្រួសារគាត់ និងអាយ៉ងយួនដែលគាត់បានជួយជ្រោមជ្រែងឲ្យស្របច្បាប់រហូតមក?

តើយើងបាត់បង់ទឹកដីដោយសារយួន ឬដោយសារ សីហនុ និងអាយ៉ងយួន ដែលធ្វើការដោះដូរជាមួយយួនដើម្បីប្រយោជន៍ផ្ទាល់ខ្លួនគេ?

តើយើងរស់នៅក្រោមអំណាចពួកឃាតករកុម្មុយនីស្តសព្វថ្ងៃនេះ ដោយសារតែយួន ឬក៏ដោយសារ ស៊ីហនុ រួមដៃជាមួយអាយ៉ងជិះជាន់យើង?